# មេរៀនទី ៣៤៖ អាប់រ៉ាមដើរតាមការបង្ហាញផ្លូវរបស់ព្រះ

លោកុប្បត្តិ ១២៖១-៨

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/Dz1Dt6rsMGw

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/5cXX7PdLtMg

**គោលបំណង៖ ព្រះជាម្ចាស់ជាអ្នកនាំផ្លូវរបស់យើង។**

**ខគម្ពីរចងចាំ៖ សុភាសិត ១៦៖៣** *"ចូរទុកដាក់អស់ទាំងការឯង នៅនឹងព្រះយេហូវ៉ាចុះ នោះអស់ទាំងគំនិតរបស់ឯង នឹងបានសំរេច។"*

**ចំរៀង** ( *យូធូបលីង* )៖

១. លោកតាអាប្រាហាំ https://youtu.be/OAuJ7i82odA

២. ខ្ញុំដើរតាមព្រះយេស៊ូវ https://youtu.be/aasilZXGorc

៣. ខ្ញុំបានសម្រេចចិត្ត https://youtu.be/MR1Yv--Q4oo

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត «ឧបសគ្គ»**



សម្ភារៈដែលត្រូវការ៖ ម៉ាស ក្រដាសផ្នូលរួចមួយចំនួន

១. ប្រើម៉ាសដើម្បីបិតភ្នែករបស់កុមារគ្រប់គ្នា។

២. គ្រូត្រូវដាក់ក្រដាសនៅលើឥដ្ឋ ហើយប្រាប់កុមារថាវាជាគ្រាប់បែក

៣. គ្រូនឹងដឹកនាំកុមារទាំងអស់ឲ្យដើរនៅក្នុងថ្នាក់រៀន ដោយមិនឲ្យកុមារជាន់លើក្រដាសគ្រាប់បែកនោះទេ។ ដូច្នេះវាគឺពិតជាមានសារៈសំខាន់ណាស់ ក្នុងការស្តាប់តាមការណែនាំរបស់គ្រូ។

៤. ប្រសិនបើកុមារណាម្នាក់ មិនស្តាប់តាមការណែនាំរបស់គ្រូ ហើយជាន់លើគ្រាប់បែកនោះ ល្បែងនេះនឹងចប់។ ប្រសិនបើកុមារទាំងអស់មិនបានដើរជាន់លើក្រដាសគ្រាប់បែកនោះទេ ពួកគេនឹងឈ្នះល្បែងនេះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ពួកគេត្រូវតែដើរតាមការដឹកនាំរបស់គ្រូ ដូច្នេះពួកគេនឹងមិនដើរជាន់លើគ្រាប់បែកនោះទេ។ ក៏ដូចគ្នានេះដែល យើងត្រូវតែដើរតាមទិសដៅរបស់ព្រះ ពីព្រោះទ្រង់ តែងតែការពារដល់ពួកយើង។ ថ្ងៃនេះយើងនឹងរៀនពីបុរសម្នាក់នៅក្នុងព្រះគម្ពីរ ដែលដើរតាមការដឹកនាំរបស់ព្រះ។

**៤. ការណែនាំមេរៀន**

បើសិនជាមានអ្នកណាម្នាក់មកប្រាប់អ្នកឱ្យពីទៅនៅទីតាំងផ្សេង ដោយមិនបានប្រាប់ពីទីតាំងជាក់លាក់ដែលអ្នកត្រូវទៅនោះ តើអ្នកនឹងធ្វើយ៉ាងដូចម្តេច? តើអ្នកនឹងចាកចេញពីក្រុមគ្រួសារ, ផ្ទះសម្បែង, មិត្តភក្តិ និងអ្វីគ្រប់យ៉ាងដែលអ្នកមាន ហើយសុខចិត្តទៅកាន់ទីកន្លែងថ្មីដែលអ្នកមិនស្គាល់ច្បាស់នោះដែរឬទេ? ថ្ងៃនេះ យើងនឹងរៀនពីបុរសម្នាក់ដែលបានលះបង់ផ្ទះសម្បែងរបស់គាត់ដើម្បីស្តាប់តាមព្រះជាម្ចាស់ ពីព្រោះគាត់បានជឿថាព្រះគឺជាអ្នកនាំផ្លូវរបស់គាត់!

**៥. រឿងនៅក្នុងព្រះគម្ពីរ**

រឿងនៅក្នុងព្រះគម្ពីរនៅថ្ងៃនេះគឺនិយាយពីបុរសម្នាក់ឈ្មោះថាអាប់រ៉ាម។ អាប់រ៉ាមបានធ្វើដំណើរជាមួយប្រពន្ធ, ឪពុក និង ក្មួយប្រុសរបស់គាត់ដោយបានចាកចេញពីផ្ទះរបស់គាត់នៅអ៊ើរទៅកាន់ទីក្រុងហារ៉ាន។ នៅពេលដែលក្រុមគ្រួសាររបស់គាត់បានតាំងទីលំនៅនៅហារ៉ានរួចរាល់ហើយអាប់រ៉ាមបានគិតថា គាត់

នឹង ត្រូវរស់នៅទីនេះពេញមួយជីវិតរបស់គាត់តែម្តង។ ប៉ុន្តែនៅថ្ងៃមួយ នៅពេលដែលគាត់មានអាយុ ៧៥ ឆ្នាំ ព្រះបានមានបន្ទូលឱ្យគាត់ចាកចេញពីទីក្រុងដែលគាត់បានហៅថាជាផ្ទះ ព្រមទាំងក្រុមគ្រួសារ ដែលបានតាំងទីលំនៅនៅទីនោះជាមួយគាត់។ ទ្រង់បានប្រាប់អាប់រ៉ាមថា ទ្រង់នឹងបង្ហាញអាប់រ៉ាមនូវទឹកដីថ្មីមួយទៀត។

ដូច្នេះ អាប់រ៉ាមនិងប្រពន្ធបានរៀបចំសម្លៀកបំពាក់និងសំភារៈប្រើប្រាស់ព្រមទាំងប្រមូល ហ្វូងសត្វ របស់ពួកគេទៅជាមួយផងដែរ។ ហើយគេក៏បានសុំឱ្យក្មួយរបស់អាប់រ៉ាមឈ្មោះឡុតបានទៅ ជាមួយនឹងពួកគេផងដែរ។ បន្ទាប់មកពួកគេក៏បានចាប់ផ្តើមធ្វើដំណើរទៅកាន់ទីកន្លែងដែលព្រះបាននាំគេទៅ។ អាប់រ៉ាម ព្រមទាំងប្រពន្ធ និងក្មួយរបស់គាត់បានដើរហើយដើរទៀតនៅក្នុងដំណើររបស់ពួកគេនេះ។

នៅក្នុងកំឡុងពេលនោះ ការធ្វើដំណើរផ្លូវឆ្ងាយគឺវាមានគ្រោះថ្នាក់ណាស់ ជាពិសេសនៅពេលដែលត្រូវធ្វើដំណើរជាមួយនឹងហ្វូងសត្វ ពីព្រោះនឹងមានពួកចោរចូលមកលួចសត្វរបស់ពួកគេ។ ពេលខ្លះ ពួកចោរបានវាយធ្វើបាបដល់ម្ចាស់របស់សត្វទាំងនោះ ដើម្បីឱ្យពួកគេអាចលួចយកទាំងសត្វ និងទ្រព្យសម្បត្តិរបស់ពួកគេថែមទៀតផង។ ប៉ុន្តែអាប់រ៉ាមបានទុកចិត្តព្រះដោយឱ្យទ្រង់គឺជាអ្នកនាំផ្លូវគាត់។ពួកគេបានធ្វើដំណើរអស់រយៈពេលជាច្រើនថ្ងៃរហូតដល់ពួកគេបានទៅដល់កន្លែងដែលព្រះបាននាំគេទៅនោះ។ ហើយនៅទីបំផុតពួកគេក៏បានទៅដល់ទឹកដីថ្មីដែលជាផ្ទះរបស់ពួកគេ ហើយព្រះបានការពារគេតាំងពីចេញដំណើររហូតមក។

នៅពេលដែលអាប់រ៉ាមចេញដំណើរមកគាត់មិនមានផែនទីនោះទេ។ គាត់បានចាកចេញពីផ្ទះរបស់គាត់នៅហារ៉ានដើម្បីធ្វើដំណើរទៅកាន់កន្លែងមួយដែលព្រះបានសន្យាថានឹងប្រទានដល់គាត់។ បើទោះបីជាអាប់រ៉ាមមិនដឹងថាគាត់នឹងទៅកន្លែងណា ឬ ទៅដោយរបៀបណាក៏ដោយ ប៉ុន្តែគាត់បានទុកចិត្តដល់ព្រះថាទ្រង់គឺជាអ្នកនាំផ្លូវរបស់គាត់។ ហើយព្រះជាម្ចាស់ក៏បានជ្រាបយ៉ាងច្បាស់ផងដែរថា ទ្រង់នឹងនាំអាប់រ៉ាមទៅណា តាំងពីពេលដែលគាត់បានចាកចេញពីហារ៉ានមកម្លេះ បើទោះបីជាអាប់រ៉ាមមិនដឹងពីការនោះក៏ដោយ។ ការណែនាំរបស់ព្រះគឺតែងតែធ្វើឱ្យយើងមានទំនុកចិត្តជានិច្ច។

យើងរាល់គ្នាសុទ្ធតែត្រូវការការណែនាំរបស់ព្រះ។ មនុស្សគ្រប់គ្នាគឺមិនដូចគ្នានោះទេ។ យើងជួបនឹងបញ្ហាផ្សេងៗគ្នា, មានក្រុមគ្រួសារខុសៗគ្នា និងមានសេចក្តីតម្រូវការខុសគ្នាផងដែរ។ ប៉ុន្តែព្រះ តែងតែយកចិត្តទុកដាក់ជាមួយនឹងយើងរាល់គ្នាជានិច្ច។ ហើយទ្រង់តែងតែចង់ធ្វើជាអ្នកនាំផ្លូវដ៏ពិសេស សម្រាប់គ្រប់គ្នា។ ព្រះអាចនាំយើងឱ្យធ្វើនូវអ្វីដែលយើងនឹកស្មានមិនដល់ ប៉ុន្តែទ្រង់គឺជាអ្នកនាំផ្លូវដ៏ល្អបំផុត ពីព្រោះទ្រង់ជ្រាបពីអ្វីគ្រប់យ៉ាងដែលបានកើតឡើង និង អាចនឹងកើតឡើងចំពោះយើងគ្រប់គ្នា។ ព្រះទ្រង់ គឺល្អបំផុតដែលដឹកនាំយើងឱ្យឆ្លងកាត់រឿងគ្រប់យ៉ាងនៅក្នុងជីវិត។ ហើយអ្វីដែលយើងត្រូវធ្វើគឺទុកចិត្ត និងដើរតាមការដឹកនាំរបស់ទ្រង់មិនថាទ្រង់នាំយើងទៅទីណានោះឡើយ។

## ៦. សំនួរពិភាក្សា

១. តើអាប់រ៉ាមកំពុងរស់នៅឯណានៅពេលដែលព្រះបានឱ្យគាត់ផ្លាស់ទីលំនៅនោះ? *(ហារ៉ាន)*

២. តើអ្នកណាខ្លះដែលចេញដំណើរទៅជាមួយនឹងអាប់រ៉ាម? *(អាប់រ៉ាម, ប្រពន្ធ និង ក្មួយប្រុសរបស់គាត់)*

៣. ហេតុអ្វីបានការធ្វើដំណើរផ្លូវឆ្ងាយនៅជំនាន់នោះមានគ្រោះថ្នាក់? *(មានចោរជាច្រើនដែលអាចវាយប្រហារ និងលួចនូវទ្រព្យសម្បត្តិរបស់ពួកគេ)*

៤. នៅពេលដែលអាប់រ៉ាមទុកចិត្តថាទ្រង់គឺជាអ្នកនាំផ្លូវរបស់គាត់តើមានរឿងអ្វីកើតឡើង? *(ព្រះទ្រង់ការពារគាត់ ហើយនាំគាត់ទៅកាន់ទីកន្លែងដែលទ្រង់បានរៀបចំសម្រាប់គាត់)*

៥. តើអ្នកណាដែលអ្នកអាចទុកចិត្តឱ្យធ្វើជាអ្នកនាំផ្លូវរបស់អ្នក? *(ព្រះ)*

## ៧. ល្បែងកំសាន្ត «ស្វែករកក្រុម»

សម្ភារៈដែលត្រូវការ៖ ក្រដាសដែលសរសេរពាក្យថា ឆ្មា ឆ្កែ គោ ជ្រូក ទា មាន់

១. ឲ្យក្រដាសដែលបានសរសេរឈ្មោះសត្វនៅលើនោះទៅកុមារម្នាក់ មួយសន្លឹក




២. នៅពេលដែលគ្រូរាប់ "១ ២ ៣" កុមារមានពេល២នាទីក្នុងការស្វែង រកក្រុមរបស់ គេដោយធ្វើសម្លេងសត្វ ដែលគេចាប់បាន។ ពួកគេមិនអាចនិយាយឈ្មោះសត្វ ឬក៏បង្ហាញ ក្រដាសដែលគេចាប់បាននោះទេ។




៣. ២នាទីក្រោយមកគ្រូនឹងនិយាយថា "ឈប់" ហើយកុមារគ្រប់គ្នាត្រូវតែអង្គុយចុះ។ គ្រូនឹងឆែកមើលក្រដាសដែលពួកគេមានថាត្រូវតាមក្រុមដែលឬទេ។ ក្រុមណាដែលអង្គុយត្រូវតាម ក្រដាសដែលពួកគេមាន នោះក្រុមគេនឹងឈ្នះល្បែងនេះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ពួកគេនឹងធ្វើបានល្អប្រសិនបើគេធ្វើតាមការណែនាំ របស់គ្រូ។ នៅពេលដែលយើងដើរតាមការណែនាំរបស់ព្រះ នោះយើងនឹងជោគជ័យគ្រប់កិច្ចការទាំងអស់ ដែលយើងធ្វើ។

**៨. ខគម្ពីរចងចាំ**

***សុភាសិត ១៦៖៣*** *"ចូរទុកដាក់អស់ទាំងការឯង នៅនឹងព្រះយេហូវ៉ាចុះ នោះអស់ទាំងគំនិតរបស់ឯងនឹងបានសំរេច។"*

**៩. ហត្ថកម្ម** **«អាប់រ៉ាមដើរតាមការបង្ហាញផ្លូវរបស់ព្រះ »**

សំភារៈដែលត្រូវការ៖ សូមបោះពុម្ពក្រដាសហត្ថកម្ម, កូល័រទៀន, កន្ត្រៃ និង ការបិត

១. ចែកក្រដាសហត្ថកម្មឱ្យកុមារម្នាក់មួយ រួចឱ្យពួកគេផាត់ពណ៌

២. ឱ្យសិស្សសរសេរនូវខគម្ពីរចងចាំនៅលើរូបវ៉ាលី។

៣. សូមកាត់រូបទាំងអស់ចេញមក ហើយបិតភ្ជាប់វ៉ាលីនោះចូលគ្នា។ ដាក់សំភារៈផ្សេងចូលទៅក្នុងវ៉ាលី។

៤. សូមពន្យល់កុមារថា អាប់រ៉ាមទុកចិត្តថាទ្រង់ជាអ្នកនាំផ្លូវរបស់គាត់នៅពេលដែលគាត់បានចាកចេញពីទឹកដីកំណើតរបស់គាត់។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

ព្រះយេស៊ូវបានបង្រៀនយើងពីរបៀបដែលឱ្យយើងទុកចិត្តព្រះ ហើយបញ្ជាក់ថាព្រះនឹងមិនឱ្យយើងដួលចុះនោះឡើយ។ សូមគិតពីបទពិសោធន៍ដែលជំរុញអ្នកឱ្យទុកចិត្តព្រះ។ បើគិតតាំងពីពេលនោះរហូតមកដល់ពេលនេះ តើកម្រិតនៃការទុកចិត្តរបស់អ្នកខុសគ្នាកម្រិតណាដែរ? សូមសញ្ជឹងគិតពីរឿងនេះ ហើយរៀបចំចិត្តរបស់អ្នកដើម្បីអាចលើកទឹកចិត្តដល់សិស្សរបស់អ្នកឱ្យពួកគេទុកចិត្តព្រះគ្រប់រឿងទាំងអស់។ ទន្ទឹមនឹងនោះ សូមអធិស្ឋានសម្រាប់សិស្សរបស់អ្នក ទូលសូមដល់ព្រះឱ្យទ្រង់បានផ្តល់នូវកម្លាំង និង ជួយជំរុញចិត្តសិស្សនោះឱ្យទុកចិត្តដល់ព្រះ។

# អាប់រ៉ាមដើរតាមការបង្ហាញផ្លូវរបស់ព្រះ






